សមាគមធនាគារនៅកម្ពុជា
THE ASSOCIATION OF BANKS IN CAMBODIA

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
Cambodia Microfinance Association

# សេចក្តីថ្លែងការណ៍រួម

**រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២៖** សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានយល់ជ្រាបពីរបាយការណ៍ស្រាវជ្រាវមួយស្តីពី «មីក្រូហិរញ្ញវត្ថុនៅកម្ពុជា៖ ការអភិវឌ្ឍ បញ្ហាប្រឈម និងអនុសាសន៍នានា» ក្រោមការគាំទ្ររបស់ក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច (BMZ)។

ការសិក្សានេះ បានបង្ហាញយ៉ាងច្បាស់ថា វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា បានចូលរួមចំណែកជាវិជ្ជមានធំធេង និងធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា (អតិថិជនទទួលសេវាធនាគារ និងហិរញ្ញវត្ថុ) មានភាពប្រសើរឡើង ជាពិសេសលើការបង្កើនប្រាក់ចំណូល និងកម្មសិទ្ធិដីធ្លី។ ការសិក្សាដដែលក៏បានបញ្ជាក់ដែរថា៖ «អ្នកចូលរួមឆ្លើយសំណួរភាគច្រើនលើសលប់ បានទទួលផលល្អវិជ្ជមានពីកម្ចីនាពេលបច្ចុប្បន្ន ។ ក្នុងនោះ គួរកត់សម្គាល់ «កំណើនប្រាក់ចំណូល» ជាចំណុចទី១ដែលពួកគាត់បានលើកឡើងមុនគេ...។» ជាងនេះទៅទៀត ការសិក្សាក៏បានបង្ហាញយ៉ាងច្បាស់ដែរថា៖ «អតិថិជនយល់ឃើញថា កម្ចីភាគច្រើនបានផ្តល់ផលវិជ្ជមានជាច្រើន និងយ៉ាងខ្លាំងសម្រាប់ពួកគាត់ ។ មិនត្រឹមតែប៉ុណ្ណោះ ពួកគាត់ចាត់ទុកថាទំនាក់ទំនងជារួម ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ ក៏មិនមានទិដ្ឋភាពណាមួយជាបញ្ហាអ្វីនោះដែរ។»

បន្ថែមពីលើផលវិជ្ជមានដែលបានលើកឡើង ការសិក្សានេះក៏បានអះអាងដែរថា ឥណទានស្ទើរតែមិនមែនជាហេតុផលចម្បង ដែលនាំឱ្យមានពលកម្មកុមារ ឬការធ្វើចំណាកស្រុកនោះទេ។ ផ្ទុយទៅវិញ អតិថិជនឥណទានភាគច្រើនទទួលផលវិជ្ជមានជាច្រើន រួមមានការកើនឡើងប្រាក់ចំណូល និងកម្មសិទ្ធិដីធ្លីជាដើម។

ទោះជាយ៉ាងនេះក្តី ការសិក្សាក៏បានរកឃើញនូវករណីអវិជ្ជមានមួយចំនួនផងដែរ ទាក់ទងនឹងការវាយតម្លៃឥណទាន ការផ្សព្វផ្សាយយ៉ាងសម្បើម និងការលក់ដីធ្លីសម្រាប់សងឥណទានជាដើម។ ប៉ុន្តែចំពោះការលក់ដីធ្លីដែលរកឃើញ គឺមានប្រមាណ ១,២ភាគរយប៉ុណ្ណោះក្នុងមួយឆ្នាំ ហើយអ្នកស្រាវជ្រាវបញ្ជាក់យ៉ាងច្បាស់ថា៖ «មិនមែនរាល់ការលក់ដីធ្លីទាំងនោះ សុទ្ធតែតំណាងឱ្យការក្សៀយធន់ផ្នែកសេដ្ឋកិច្ច និងសង្គមរបស់គ្រួសារអតិថិជនប៉ុណ្ណោះទេ ប៉ុន្តែមួយចំណែកពាក់ព័ន្ធនឹងការវិវត្តនៃតម្លៃដីធ្លីក្នុងប្រទេសកម្ពុជាផងដែរ។»

សមាគមទាំងពីរបានយល់ និងទទួលយកនូវក្តីបារម្ភមួយចំនួន ដែលត្រូវបានលើកឡើងក្នុងរបាយការណ៍សិក្សានេះ។ សមាគមទាំងពីរ យល់ឃើញថា ព្រំដែននៃការសិក្សានេះ មិនបានឆ្លុះបញ្ចាំងរូបភាព

ទាំងស្រុងនៃវិស័យនេះឡើយទេ។ នេះអាចបណ្តាលមកពីការកំណត់និយមន័យខុសគ្នានូវពាក្យ «បំណុលច្រើនលើសលប់» ឬទៅលើទិដ្ឋភាពខុសគ្នានៃបរិបទវិស័យមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ជាដើម។

សមាគមទាំងពីរ ពិតជាមានការសោកស្តាយយ៉ាងខ្លាំងចំពោះស្ថាប័នមួយចំនួន ដែលបានផ្សព្វផ្សាយជាសាធារណៈក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួន ដោយផ្តោតសំខាន់តែលើទិដ្ឋភាពអវិជ្ជមាន ដោយមិនបានបង្ហាញនូវខ្លឹមសារសំខាន់រួមក្នុងរបាយការណ៍សិក្សា ដែលជាហេតុបណ្តាលអោយមានការភ័ណ្ឌច្រឡំក្នុងចំណោមសាធារណៈមតិ។

អ្វីដែលសំខាន់ជាងនេះទៅទៀត យើងខ្ញុំសូមធានានូវការប្តេជ្ញាចិត្តចំពោះការផ្តល់ឥណទានប្រកបដោយការទទួលខុសត្រូវ ដែលតែងតែជាបេសកកម្មស្នូលនៅក្នុងវិស័យហិរញ្ញវត្ថុទាំងមូល។ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងដៃគូពាក់ព័ន្ធនានា តែងតែបាននិងបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការធានាឱ្យបាននូវការរីកចម្រើនវិស័យហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព និងការចូល រួមចំណែកជាវិជ្ជមានដល់អតិថិជនផងដែរ។ ភ័ស្តុតាងដែលមានស្រាប់ ដូចជាការដាក់ចេញនូវគោលការណ៍ផ្តល់ឥណទាន ក្រមប្រតិបត្តិសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ វគ្គបណ្តុះបណ្តាលប្រធានសាខាថ្នាក់ខេត្តនិងតំបន់ ស្តង់ដារួមសម្រាប់កិច្ចសន្យាឥណទាន កម្មវិធីពង្រឹងសមត្ថភាពស្តីពីឥណទានប្រកបដោយទំនួលខុសត្រូវ ក៏ដូចជាការពង្រឹងសិទ្ធិអំណាចអតិថិជនតាមរយៈកម្មវិធីចំណេះដឹងហិរញ្ញវត្ថុ។

បន្ថែមលើវិធានការណ៍ និងគំនិតផ្តួចផ្តើមខាងលើ សមាគមនឹងអញ្ជើញស្ថាប័នអន្តរជាតិ ឯករាជ្យមួយ ក្នុងការសិក្សាអោយបានស៊ីជម្រៅលើទិដ្ឋភាពរួមនៃវិស័យមីក្រូហិរញ្ញវត្ថុផងដែរ៕

**ព័ត៌មានបន្ថែម** សូមទាក់ទង៖


- លោក សុខ ចាន់ នាយកបរិយាបន្នហិរញ្ញវត្ថុ និងទំនាក់ទំនងសាធារណៈ នៃសមាគមធនាគារនៅកម្ពុជា តាមរយៈទូរសព្ទលេខ ០៩២ ៦៨៣ ៣៣០ ឬ អ៊ីមែល abc_fi@abc.org.kh
- លោក កាំង តុងងី ប្រធាននាយកដ្ឋានទំនាក់ទំនងនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា តាមរយៈទូរសព្ទលេខ ០៩៥ ២៦២ ១១១ ឬ អ៊ីមែល hcd@cma-network.org